# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាបុណ្យឆ្លងព្រះវិហារសន្តិតេរេសានៃព្រះកុមារយេស៊ូព្រៃកប្បាស
# ថ្ងៃទី២៥ កុម្ភៈ ២០១៧

អត្ថបទទី១៖ អស ៦៦,១០-១៤
អត្ថបទទី២៖ រ៉ូម ៨,១៤-១៧
ដំណឹងល្អ៖ មថ ១៩,១៣-១៥

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះយើងមានអំណរសប្បាយជួបជុំគ្នា នៅលើទឹកដីព្រះសហគមន៍សន្តិតេរេសានៃព្រះកុមារយេស៊ូព្រៃកប្បាស ដែលជាព្រះសហគមន៍ថ្មីមួយនៅក្នុងមណ្ឌលសកម្មភាពតាកែវ។ ដំបូងឡើងក្នុងមណ្ឌលសកម្មភាពតាកែវ យើងបានចាប់ផ្តើមជាមួយលោកគ្រូជៀងនៅចំការទៀង ក្រោយមកទៅប្រកាសដំណឹងល្អនៅគិរីវង់ដែលមានលោកតាចយនៅឆ្នាំ២០០៣។ បន្ទាប់មកយើងមាននៅព្រៃកប្បាសនេះដែលមានលោកគ្រូផា គាត់បានទទួលការអប់រំពីសាលាដុនបូស្កូនៅភ្នំពេញថ្មី។ ពេលគាត់មកស្រុកកំណើតវិញ គាត់បានបង្កើតថ្នាក់រៀនភាសាអង់គ្លេស ថ្នាក់រៀនកុំព្យូទ័រ ដោយបានប្រមូលយុវជនខ្លះៗដើម្បីបង្រៀនអំពីព្រះយេស៊ូខ្លះៗរហូតមានថ្នាក់រៀនអប់រំជំនឿ នេះជារបៀបបង្កើតព្រះសហគមន៍ថ្មី។ យើងមានលោកឪពុក ដូស្ស ដែលទទួលមណ្ឌលសកម្មភាពតាកែវនៅផ្ទះលោកគ្រូផា មានសត្វគ្រប់មុខ និងមានរោងមួយដើម្បីអប់រំជំនឿនិងអធិដ្ឋាន។ ក្រោយមកទើបលោកគ្រូផា និងលោកគ្រូជៀងស្នើទៅលោកឪពុកដូស្ស ដើម្បីរកដីតូចមួយ ក្រោយមកលោកឪពុកនិយាយមកខ្ញុំឲ្យមកមើលដីនេះ ដែលកាលនោះមានដើមស្វាយ៣៣០ដើម និងមានស្រែជុំវិញដើមស្វាយ មានត្រពាំងទឹកធំមួយ។ ក្រោយពេលខ្ញុំឃើញដីនេះខ្ញុំស្រឡាញ់ណាស់ ដោយសារមានគ្រប់អ្វីៗទាំងអស់ហើយនៅជិតភ្នំជីសូរទៀត។ ពេលប្រជុំជាមួយទីប្រឹក្សាខ្ញុំហើយ ក៏សម្រេចចិត្តទិញដីនេះដើម្បីធ្វើមណ្ឌលសំណាកធម៌សម្រាប់ភូមិភាគភ្នំពេញផង និងសម្រាប់ព្រះសហគមន៍ព្រៃកប្បាសផង។ ក្រោយមកមានលោកឪពុកអាន ដែលបម្រើនៅមណ្ឌលសកម្មភាពតាកែវ និងទទួលខុសត្រូវនៅកន្លែអនេះតែម្តង។ ខ្ញុំបានប្រគល់បេសកកម្មមួយឲ្យគាត់ គឺធ្វើយ៉ាងណាដើម្បីសាងសង់មណ្ឌលសំណាក់ធម៌តាមរបៀបស្អាតដែលស៊ីនឹងធម្មជាតិដោយសាម័ញ្ញ ដែលណែនាំឲ្យបងប្អូនសប្បាយចិត្តមកលេងចេញចូល។ ក្រោយមកគាត់បានសាងសង់បឹងហ្គាឡូ៩ តាមរយៈការជួយឧបត្ថមរបស់ព្រះសហគមន៍ប្រទេសថៃ ក្រោយមកលោកឪពុកគាត់គាត់ធ្វើសាលាមត្តេយ្យមួយដើម្បីអប់រំកូនក្មេង គាត់បានធ្វើដោយមានការឧបត្ថមពីក្រុមចនដូនើរ ។ ពេលមាននេះអស់ហើយគាត់ថានៅខ្វះព្រះវិហារមួយ ខ្ញុំបានប្រាប់គាត់ថា ខ្ញុំមាន១០០០០$ (មួយម៉ឺនដុល្លា) សូមធ្វើព្រះវិហារតូចមួយតាមចំនួនទឹកប្រាក់ដែលយើងមាន។ លុយនេះខ្ញុំបានទទួលពីលោកតានៅបារាំងម្នាក់ គាត់បានឲ្យលុយនេះធ្វើព្រះវិហារមួយឈ្មោះសន្តិតេរេសានៃព្រះកុមារយេស៊ូ លោកឪពុកក៏បានឯកភាព

ឲ្យដាក់ឈ្មោះនេះ។ លោកឪពុកក៏បានសាងសង់ព្រះវិហារនេះ ដែលជាព្រះវិហារមួយពិសេសដោយសារជាព្រះវិហារដែលសាងសង់ដោយដីឥដ្ឋ អង្កាម ចំបើង ទឹក ជាស្នាដៃរបស់យុវជនយុវនារីនៅទីនេះ និងមានយុវជនខ្លះៗក្នុងភូមិភាគភ្នំពេញក៏បានមកជួយផងដែរ។ យើងបានចាប់ផ្តើមធ្វើឥដ្ឋមួយៗរហូតអាចដំលើងព្រះវិហារនេះបាន ជាព្រះវិហារពិសេសដោយសារបងប្អូនគ្រីស្តបរិស័ទដែលបានជួយគ្នាក្នុងការកសាង ដោយពលកម្មរបស់គេ ដោយកម្លាំងរបស់គេ។ ព្រះវិហារនេះកក់ក្តៅ ដែលណែនាំឲ្យយើងចេញចូលនៅក្នុងអំណរសប្បាយនិងសេចក្តីសុខ យើងបានដាក់ឈ្មោះព្រះវិហារសន្តីតេរេសានៃព្រះកុមារយេស៊ូ ដែលជាសន្តីម្នាក់បានណែនាំឲ្យយើងយល់ថាជីវិតរបស់យើងត្រូវជាជីវិតដែលទីពឹងទាំងស្រុងទៅលើព្រះជាម្ចាស់។ នៅពេលខ្ញុំតែងតាំងព្រះវិហារនេះឲ្យទៅជាព្រះវិហាររបស់ព្រះជាម្ចាស់ យើងបានរំលឹកអំពីមូលហេតុយើងមានព្រះវិហារ។ ព្រះវិហារជាកន្លែងដែលយើងរួមគ្នាអធិដ្ឋាន ជាកន្លែងដែលយើងលើកតម្កើងសេរីរុងរឿងរបស់ព្រះជាម្ចាស់ ជាកន្លែងដែលយើងស្តាប់ព្រះបន្ទូលព្រះអង្គ ជាកន្លែងដែលយើងទទួលអគ្គសញ្ញានានាមកពីព្រះអង្គ។ ព្រះវិហារនេះ ជាកន្លែងដើម្បីជួយយើងឲ្យយើងទៅជាមនុស្សដ៏វិសុទ្ធ ជួយយើងដើម្បីឲ្យយើងទៅជាមនុស្សថ្មី។ សព្វថ្ងៃយើងមិនទាន់មានគ្រីស្តបរិស័ទច្រើន បន្តិចម្តងៗកន្លែងនេះជាកន្លែងមួយទៅជាពន្លឺសម្រាប់បងប្អូនឯទៀតៗ។ ខ្ញុំរំលឹកឲ្យគ្រីស្តបរិស័ទយុវជនយុវនារីនៅទីនេះ យើងជាពូជគ្រីស្តបរិស័ទលើទឹកដីយើងរួមជាមួយលោកឪពុល ដែលសព្វថ្ងៃយើងមានលោកឪពុកសាន់ដេ ធ្វើយ៉ាងណាដើម្បីឲ្យព្រះសហគមន៍របស់យើងទៅជាកន្លែងមួយ ដែលណែនាំបងប្អូនឯទៀតៗរកឃើញពន្លឺនៅក្នុងជីវិត។ មានន័យថា ជាកន្លែងមួយដែលណែនាំឲ្យយើងយល់អំពីតម្លៃរបស់មនុស្ស នៅជុំវិញយើងមានកូនក្មេងច្រើន មានយុវជនច្រើន ចាស់ជរាច្រើន មានកសិករ មានអ្នកក្រីក្រ ធ្វើណាយ៉ាងឲ្យកន្លែងនេះទៅជាកន្លែងមួយដែលអាចនិយាយថា ពន្លឺនៃសេចក្តីសង្ឃឹមសម្រាប់បងប្អូនឯទៀត។ នេះជាតួនាទីរបស់យើងជាគ្រីស្តបរិស័ទ ទោះបីយើងនៅគ្នាតិចឲ្យយើងបង្កើតគ្រួសារមួយដែលចេះសហការគ្នាដែលចេះជួយគ្នាទៅវិញទៅមក ដើម្បីកន្លែងនេះទៅជាកន្លែងមួយដែលណែនាំបងប្អូនរកឃើញសេចក្តីសង្ឃឹម។ យើងមានសាលាមត្តេយ្យ យើងមានមកម្មវិធីកាយបូទ្ធិ យើងមានកម្មវិធីចុះតាមភូមិ មានកម្មវិធីសួរសុខទុក្ខអ្នកជំងឺ ដោយដឹងថាព្រះជាម្ចាស់គង់នៅជាមួយយើង ដើម្បីឲ្យកន្លែងនេះជាព្រះដំណាក់របស់ព្រះជាម្ចាស់។ ពេលយើងចាប់ផ្តើកន្លែងថ្មីមួយ យើងដឹងថាតល្វនេះព្រះជាម្ចាស់បានជ្រើសរើសកន្លែងនេះ ដើម្បីណែនាំឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាពន្លឺសម្រប៉ាបងប្អូនឯទៀតៗ។ វត្តមានរបស់ព្រះជាម្ចាស់មកដល់ហើយ មិនមែនដោយសារយើងមានអាគារនេះគឺដោយសារយើងមានគ្រីស្តបរិស័ទខ្លះៗដែលនិយាយថាខ្ញុំយកព្រះបន្ទូលជាទីពឹង ខ្ញុំយកព្រះសហគមន៍ជាទីពឹង ខ្ញុំយកព្រះគ្រីស្តជាទីពឹង។ ពេលបងប្អូននិយាយដូចនេះនៅកន្លែងរបស់គេផ្ទាល់មានន័យណាស់ ព្រះបន្ទូលរបស់ព្រះជាម្ចាស់កំពុងណែនាំយើងឲ្យទៅជាវត្តមានរបស់ព្រះជាម្ចាស់

សម្រាប់បងប្អូនឯទៀត។ ដើម្បីធ្វើជាមនុស្សដ៏វិសុទ្ធពិតមែន ដូចយើងស្តាប់ថា "**សូមទ្រង់ប្រទានឲ្យគេមានចិត្តសប្បុរសដើម្បីជួយសម្រាលទុក្ខអ្នកស្រេកឃ្លាន អ្នកដែលត្រូវគេសង្កត់សង្កិន និងផ្តល់សេចក្តីសង្ឃឹមដល់អ្នកកំសត់ទុរគត**"។ ដូច្នេះពីមួយថ្ងៃទៅមួយថ្ងៃយើងត្រូវការភ្ញាក់ស្មារតីថែមទៀត យើងត្រូវការបើកត្រចៀកដើម្បីស្តាប់លឺបងប្អូនដែលកំពុងស្រេកឃ្លាន ដែលកំពុងមានទុក្ខលំបាក ដែលកំពុងត្រូវគេសង្កត់សង្កិន ធ្វើយ៉ាងណាដើម្បីឲ្យគេមានជីវិត។

ពេលយើងឡើងលើភ្នំជីសូរ យើងមានអារម្មណ៍ថាយើងកំពុងមើលឃើញប្រទេសកម្ពុជាទាំងមូល មើលវាលស្រែ មើលភូមិអ្នកស្រុក មើលព្រៃព្រឹក្សា មើលផ្លូវ មើលប្រជាជនដែលកំពុងធ្វើការងារចិញ្ចឹមជីវិត ពេលយើងមើលឃើញហើយយើងអធិដ្ឋាន ខ្ញុំមកពីព្រះសហគមន៍កាតូលិកខ្ញុំបានទទួលបេសកកម្មយ៉ាងពិសេស ដោយធ្វើជាពន្លឺសម្រាបបងប្អូនឯទៀត។ ព្រះយេស៊ូមានព្រះបន្ទូលថា "**យើងជាពន្លឺនិងជាអំបិល**" យើងជាពន្លឺដែលមិនអាចលាក់បាន បន្លឺនេះត្រូវតែណែនាំឲ្យបងប្អូនមើលឃើញ។ ដូច្នេះពេលយើងចុះវិញ នៅក្នុងជីវិតប្រចាំរបស់យើង ធ្វើយ៉ាងណាធ្វើឲ្យអ្នកដទៃសប្បាយចិត្តជាមួយយើង។

ខ្ញុំគិតថាបឹងហ្គាឡូរបស់យើងមិនទាន់ប្រើល្មមទេ ដូច្នេះលោកឪពុលសាន់ដេ មិនមែនតែជាប្រធានព្រះសហគមន៍នៅទីនេះ ត្រូវធ្វើជាប្រធានសំណាក់ធម៌សម្រាប់ភូមិភាគភ្នំពេញទាំងមូល ធ្វើយ៉ាងណាឲ្យកន្លែងនេះមានជីវិត។ មានន័យថារៀបចំ ដើម្បីឲ្យមានសំណាក់ធម៌ជារៀងរាល់ពេលវេលា កន្លែងនេះជាកន្លែងសម្រាប់ភូមិភាគទាំងមូលមកដើម្បីសំណាក់ធម៌ ដើម្បីប្រជុំ ដើម្បីសិក្ខាសាលាផ្សេងៗ។ ដូច្នេះបងប្អូនអាចយកពេលនៅទីនេះ ដើម្បីនឹកឃើញដល់ជីវិតរបស់យើង ព្រោះជាកន្លែងមួយដែលយើងត្រូវស្ងៀមស្ងាត់ ដើម្បីបង្កើតទំនាក់ទំនងយ៉ាងជិតស្និតជាមួយព្រះជាម្ចាស់ ដើម្បីនឹកឃើញខ្ញុំជាបុត្រធីតារបស់ព្រះអង្គ។ យើងមានព្រះវិញ្ញាណដ៏វិសុទ្ធដែលគង់នៅជាមួយយើង យើងអាចស្រែកថាឱព្រះបិតាអើយ យើងទទួលស្គាល់ថាព្រះបិតាស្រឡាញ់យើង ព្រះបិតាថែរក្សាយើង។ កន្លែងនេះយើងមានសន្តតេរសោនៃព្រះកុមារយេស៊ូ យើងមានធាតុរបស់អ្នកម្តាយតេរេសា យើងល្មមទទួលព្រះអំណោយទានពីព្រះជាម្ចាស់ថែមទៀត ដើម្បីទទួលស្គាល់យើងជាបុត្រធីតារបស់ព្រះអង្គ ហើយយើងចង់បង្កើតព្រះសហគមន៍មួយដែលជាពន្លឺសម្រាប់បងប្អូនឯទៀតៗ។

ពេលនេះយើងអធិដ្ឋាន អរព្រះគុណព្រះជាម្ចាស់ សម្រាប់ព្រះសហគមន៍តូចដែលយើងមាននៅទីនេះ អរព្រះគុណព្រះជាម្ចាស់សម្រាប់មណ្ឌលសំណាក់ធម៌ពិសេសដែលយើងមាននៅទីនេះ អរព្រះគុណព្រះជាម្ចាស់សម្រាប់ព្រះសហគមន៍របស់យើង ដែលជាស្នាព្រះហស្តរបស់ព្រះជាម្ចាស់ ដោយសារពិតមែនព្រះជាម្ចាស់ស្រឡាញ់យើងខ្លាំងណាស់។ អាម៉ែន។